ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំនព្វមាស និងទិសដៅការងារសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០

នៅក្នុងនព្វមាស ឆ្នាំ២០២០នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I-លទ្ធផលការងារស្នូលលើមុខងារទាំង៥៖

### ១- មុខងារនីតិកម្ម

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១៣លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ចំនួន២១ច្បាប់

២-ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ចំនួន០២លើក

៣-ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យស្របនឹងតម្រូវការថ្មីរបស់ស្ថាប័ន

- បានរៀបចំចាត់ចែងប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០៧លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២១ច្បាប់

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន២២ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា និងបានចាត់ចែងតាមនីតិវិធី

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ ប្រកាស ដីកាអម សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៣,៥៥២ច្បាប់ និងបានធ្វើកំណត់បង្ហាញចំនួន២០១ច្បាប់ និងផ្សព្វផ្សាយជូនសមាជិក សមាជិកាព្រឹទ្ធសភា

- បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន២១ច្បាប់

- បានធ្វើបច្ចុប្បន្នភាពវេបសាយ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ ដែលបានធ្វើវិសោធនកម្ម និងបានអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួង ស្ថាប័ននានា ចំនួន០៨លើក៖ ក្រសួងទេសចរណ៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងធម្មការ និងសាសនា, មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ, ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, និងក្រុមសមាគមអ្នកចិញ្ចឹមសត្វនៅកម្ពុជា ដើម្បីឈ្វេងយល់អំពីការរីកចម្រើនថ្មីៗ បញ្ហាប្រឈម វិធានការនានា និងស្តាប់របាយការណ៍លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១៨លើក ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងបុព្វបទថ្មី ពិសេសការងារ ចាត់តាំង ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ, ពិនិត្យស្ថានភាពជាក់ស្តែងរបស់ឃុំ និងពិភាក្សា ដោះស្រាយទំនាស់ដីធ្លីជូនប្រជាពលរដ្ឋ, ការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក កំពង់ផែទឹកជ្រៅ និងដំណើរការរោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម, ការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ, ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន, ការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមរបស់ខេត្ត, ការផ្សព្វផ្សាយច្បាប់, ការអនុវត្តច្បាប់ និងការដោះស្រាយពាក្យបណ្តឹង, ការប្រមូលព័ត៌មានតាមវិស័យ, ការអនុវត្តកំណែទម្រង់វិមជ្ឈការ, ការគ្រប់គ្រងច្រកទ្វារអន្តរជាតិ, ផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា និងសិក្សាឈ្វេងយល់អំពីបញ្ហាប្រឈម ព្រមទាំងសំណូមពររបស់អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កំពង់ចាម តាកែវ កំពត កែប ព្រះសីហនុ ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។

### ៣- មុខងារតំណាង

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះពិនិត្យ និងបើកការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន និងនាំយកគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ ទៀនព្រះវស្សា ទេយ្យទាន ទេយ្យវត្ថុ និងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា ពិធីបុណ្យកាន់បិណ្ឌ ពិធីគោរពវិញ្ញាណក្ខន្ធសព ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៩២លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ ព្យាបាលជំងឺ និងអប់រំផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩(Covid-19) ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៨៤១លើក

- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា បានបរិច្ចាគថវិកាផ្ទាល់ខ្លួន និងប្រាក់បៀវត្សផ្ទាល់ខ្លួន គ្រឿងឧបភោគ បរិភោគ សម្ភារៈការពារ និងបានចុះអប់រំផ្សព្វផ្សាយអំពីវិធានការការពារ ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ (Covid-19) នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

- បានសហការរៀបចំវេទិកាសាធារណៈថ្នាក់ខេត្តចំនួន០៤លើក ស្តីពី ការពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ព្រមទាំងការអភិវឌ្ឍមូលដ្ឋាននៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភាធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ជូនដល់សាធារណជន សាស្ត្រាចារ្យ សិស្ស និងនិស្សិត មកពីសាកលវិទ្យាល័យ និងវិទ្យាស្ថាននានាចំនួន០៤លើក មានសិក្ខាកាមចូលរួមចំនួន៣៤៦នាក់

- អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងចូលរួមពិធីផ្សេងៗ រួមមាន៖ ចុះពិនិត្យអំពីដំណើរការការងារនៅបណ្ណាល័យ និងបណ្ណសារដ្ឋានព្រឹទ្ធសភា, ចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្និសីទជាតិអំពីរដ្ឋធម្មនុញ្ញស្តីពី គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ ដើម្បីអបអរសាទរទិវារំលឹកខួប២៧ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ចូលរួមធ្វើបទឧទ្ទេសនាមអំពីប្រព័ន្ធសភាប្រជាធិបតេយ្យ ព្រមទាំងបានជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរមូលដ្ឋាន នៅរាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ (Covid-19)

- បានទទួលពាក្យបណ្តឹងចំនួន៧២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៣២ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន៣២ករណី កំពុងពិនិត្យសិក្សាចំនួន១១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៣២ករណី និងបានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០៨ករណី ព្រមទាំងបានដោះស្រាយបញ្ចប់ចំនួន០១ករណី និងតម្កល់ទុកមិនចាត់ការចំនួន០៣ករណី ទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន៤៧ករណី

- បានចូលរួមគាំទ្របរិច្ចាគថវិកាជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន២០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និងរៀបចំអំណោយចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ កុមារកំព្រា និងជនក្រីក្រ

- បានផ្តល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនមន្ត្រីរាជការទីចាត់ការការពារព្រំដែន និងវិទ្យាស្ថានអ៊ីនធឺរេដចំនួន១៤០ក្បាល សម្រាប់សិក្សាស្រាវជ្រាវ

- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៧០១នាក់ ព្រមទាំងបានអនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន២០០ក្បាល និងសងវិញចំនួន២០០ក្បាល។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជូនសារតាំង ជំនួបសវនាការ និងសម្តែងការគួរសមរវាងថ្នាក់ដឹកនាំព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ ឥស្សរជននយោបាយ និងអគ្គទូតនានា

ចំនួន១៦លើក

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងាររវាងសមាជិក សមាជិកាព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ និងអង្គទូតនានា ចំនួន០៩លើក

- បានរៀបចំបែបបទជូនសមាជិកព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋកូរ៉េ និងអញ្ជើញទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF) លើកទី២៨ នៅប្រទេសអូស្ត្រាលី

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភាប្រជុំការងារអន្តរជាតិនានា តាមរយៈប្រព័ន្ធវីដេអូ Conference ចំនួន០៦លើក

- អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន០៧លើក និងជាអធិបតីក្នុងពិធីប្រគល់-ទទួលអំណោយមនុស្សធម៌ជាម៉ាស់ និងសម្ភារបរិក្ខារប្រើប្រាស់ពីសាធារណរដ្ឋសង្គមនិយមវៀតណាម, សាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ,និងប្រធានអង្គការការីតា, ព្រមទាំងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង(ASGPF) នៅសាធារណរដ្ឋបារាំង

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ចំនួន០២លើក រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយវិទ្យាស្ថានចក្ខុវិស័យអាស៊ី(AVI) និងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន២៦ច្បាប់

- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មានស្តីពី សភានៅលើបណ្តាប្រទេសនានា ចំនួន៨២១ប្រធានបទ

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិពាក់ព័ន្ធនឹងស្ថានភាពនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម ជារៀងរាល់ប្រចាំខែនីមួយៗចំនួន០៩ច្បាប់

- បានផលិតព័ត៌មានច្បាប់ និងនយោបាយជាច្បាប់ជាតិ និងអន្តរជាតិចំនួន២៧៩អត្ថបទ

- បានទំនាក់ទំនងជាមួយស្ថានទូតបារាំង, ស្ថានទូតរុស្ស៊ី, ស្ថានទូតឥណ្ឌា, ស្ថានទូត-ប៉ាគីស្ថាន, ស្ថានទូតម៉ាឡេស៊ី, អគ្គលេខាធិការដ្ឋានរដ្ឋសភា, ដៃគូភាគីចិន, អង្គការមូលនិធិអាស៊ី, USAID/Cambodia, វិទ្យាស្ថានចក្ខុវិស័យអាស៊ី(AVI), វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ(NIDIR), មជ្ឈមណ្ឌល(HDR), មជ្ឈមណ្ឌលអភិវឌ្ឍជនបទកម្ពុជា-កូរ៉េ(CKRDC),

សាលាភូមិន្ទរដ្ឋបាល, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ច(CDC), វិទ្យាស្ថានសាន់ហ៊ាយស៍, ក្រុមហ៊ុន HAUWEI, ក្រុមហ៊ុនKOHA, ក្រុមហ៊ុន Khmer Sport, ក្រុមហ៊ុន Cambodia Hosting, ក្រសួង ស្ថាប័ន និង បណ្ណាល័យនានា ដើម្បីស្នើសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ និងសម្រួលដល់កិច្ចការអន្តរជាតិ ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានទទួលលិខិតចូលចំនួន៨,៣៨៥ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣,៥៣៩ច្បាប់
- រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤
- បានផលិតរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ នីតិកាលទី៤
- បានផ្សព្វផ្សាយលើវិធានការសំខាន់ៗចំនួន៣ចំណុចៈ វិធានការអប់រំ និងអនាម័យ, វិធានការរដ្ឋបាល, និងវិធានការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ព្រមទាំងកម្មវិធីបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ (Covid-19 )
- បានធ្វើសេចក្តីណែនាំស្តីពី ការបង្ការការពារ និងទប់ស្កាត់ជំងឺកូវីដ១៩ ( Covid-19)
- បានតាមដាន ផលិតឯកសារសង្ខេប និងផ្សព្វផ្សាយអំពីវឌ្ឍនភាពនៃការផលិតវ៉ាក់សាំងការពារជំងឺកូវីដ១៩ (Covid-19) ចំនួន០៧ច្បាប់
- យោងតាមសារាចរណែនាំស្តីពី ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានធ្វើការប្រជុំពិភាក្សាជាមួយគណៈកម្មការទី២ព្រឹទ្ធសភា ដើម្បីការកាត់សន្សំការចំណាយក្រៅពីបន្ទុកបុគ្គលិក សម្រាប់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ១៩(Covid-19) និងទប់ទល់ផលប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ចជាតិ
- បន្តយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីជានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង
- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ និងការបោះពុម្ព
- បន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាពផលិតសេវានៅទាប
- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុចំនួន០៨លើក

- បានរៀបចំកសាងយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (២០២១-២០២៣) និងគម្រោងថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២១

- បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី គម្រោងបែងចែកកញ្ចប់ថវិកាប្រចាំឆ្នាំ២០២១ របស់ព្រឹទ្ធសភា

- បានប្រជុំត្រួតពិនិត្យ និងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពសមិទ្ធកម្ម ផែនការសកម្មភាព(Map3) និងសូចនាករសមិទ្ធកម្ម (KPIs) នៃការអនុវត្តថវិកាត្រីមាសទី២ ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំក្រុមប្រឹក្សាភិបាលវិទ្យាស្ថានសភាកម្ពុជា (PIC) ដើម្បីកំណត់ផែនការសកម្មភាព និងថវិកាអនុវត្តឆ្នាំ២០២០ ព្រមទាំងផែនការរៀបចំ (PCA) ក្នុងឆ្នាំ២០២១

- បានប្រជុំពិនិត្យស្តីពី ការងារសង្គមកិច្ច និងការងារសេវនកម្មផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំជាមួយតំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញពាក់ព័ន្ធនឹងផលប្រយោជន៍មន្ត្រីរាជការ៣ស្ថាប័ន

- បានប្រជុំការងារផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមរយៈប្រព័ន្ធវីដេអូ Conference

- បានប្រជុំពិនិត្យ និងពិភាក្សាលើគោលនយោបាយស្តីពី ការអភិវឌ្ឍធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំពិនិត្យ និងកែសម្រួលគោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាព្រឹទ្ធសភា (២០២១-២០៣០)

- បានប្រជុំគណៈកម្មការរៀបចំគ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា នៅពាក់កណ្ដាលនីតិកាលទី៤

- បានប្រជុំពិភាក្សាស្តីពី ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី១, ទី២ និងទី៣ ឆ្នាំ២០២០

- បានប្រជុំផ្សព្វផ្សាយស្តីពី ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា និងទស្សនៈវិស័យនៃដំណើរការទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល១០ឆ្នាំ(២០២១-២០៣០)

- បានប្រជុំកែសម្រួលផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០២១-២០៣០) និងកែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការងារគ្រប់គ្រងធនធានមនុស្សរបស់អគ្គនាយកដ្ឋានទាំង៩

- បានដេញថ្លៃការផ្គត់ផ្គង់ ការបោះពុម្ព សម្ភារការិយាល័យ សម្ភារអនាម័យ និងឯកសណ្ឋាន

- បានដោះស្រាយសំណើសុំសម្ភារៈ និងប្រេងឥន្ធនៈចំនួន១១៩សំណើ

- បានបើកប្រាក់បៀវត្សប្រចាំខែមករា ដល់ខែកញ្ញាឆ្នាំ២០២០, ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ, ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ, និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនរចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល

- បានធ្វើរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៩ និងដំណើរការអនុវត្តថវិកាឆ្នាំ២០២០តាមនីតិវិធី

- បានរៀបចំរបាយការណ៍ចំណូល និងចំណាយថវិកាប្រចាំឆមាសទី១ ឆ្នាំ២០២០ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានបញ្ចប់ការកសាងគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២១ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានរៀបចំតភ្ជាប់បណ្តាញប្រព័ន្ធ (FMIS) បំពាក់សម្ភារៈ និងការប្រើប្រាស់

- បង្កើន3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ដើម្បីទ្រទ្រង់ដំណើរការថវិការហូតដល់ចុងឆ្នាំ២០២០

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែនីមួយៗ និងឆមាសទី១ និងនព្វមាស ឆ្នាំ២០២០ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួង និងស្ថាប័ននានា

- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន ១,៨២២ច្បាប់, ប័ណ្ណសម្គាល់ខ្លួនចំនួន២៩៦ប័ណ្ណ, និងប័ណ្ណបេបសន្តិសុខសង្គម

- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំបែបបទបន្តកិច្ចសន្យាដល់បុគ្គលិកជាប់កិច្ចសន្យាចំនួន៨៦នាក់,វាយតម្លៃតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤៨នាក់ និងបែបបទវាយតម្លៃបេក្ខជនត្រៀមតាំងស៊ប់ក្នុងមុខតំណែងគ្រប់គ្រងក្នុងអង្គការលេខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១២នាក់

- បានរៀបចំបញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវបានវាយតម្លៃតម្លើងថ្នាក់បៀវត្សតាមវេនជ្រើសរើស និងវេនអតីតភាពសម្រាប់ឆ្នាំ២០២០

- បានធ្វើបច្ចុប្បន្នភាពបៀវត្ស និងផលប្រយោជន៍តាមការប្រែប្រួលថ្មី

- បានរៀបចំធ្វើឯកសារពិពណ៌នាការងារអំពីតួនាទី ភារកិច្ច និងការចងក្រងសៀវភៅរូបថតនិងប្រវត្តិរូបរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបោះពុម្ពលិខិតសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទរបស់

មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២០ ចំនួន២២,៥០០ច្បាប់ ព្រមទាំងរៀបចំចងក្រងសេចក្ដីសម្រេច ស្ដីពី របៀបរបបនៃការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាសៀវភៅ

- បានធ្វើលិខិតបង្គាប់ការចំនួន៤៨ច្បាប់ និងសេចក្ដីសម្រេចចំនួន៧៤ច្បាប់

- បានបើកវគ្គបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេសចំនួន២៤វគ្គ មានសិក្ខាកាមចូលរួមចំនួន៨៩៩នាក់ និងចូលរួមសិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៤លើក មានសិក្ខាកាមចូលរួមចំនួន២៦២នាក់ ព្រមទាំងទៅទស្សនកិច្ចសិក្សានៅក្រៅប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន០៥នាក់

- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី ការបង្កើត និងប្រើប្រាស់កម្មវិធី Email & Zoom ជូនលេខាធិការដ្ឋានអមគណៈកម្មការទាំង១០ព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានទទួលអាហារូបករណ៍ចំនួន០៥កន្លែង៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅវិទ្យាស្ថានអ៊ីនធីវេដ សម្រាប់ឆ្នាំសិក្សា(២០២០-២០២១)

- បានរៀបចំចងក្រងសម្រង់ព័ត៌មានតម្រូវការបណ្ដុះបណ្ដាលជំនាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមនាយកដ្ឋាននីមួយៗ និងបានចងក្រងជាសៀវភៅ

- ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារួមមាន៖ ចំណេះដឹងជំនាញ ភាសាបរទេស ការគ្រប់គ្រង/ដឹកនាំ និងបច្ចេកវិទ្យាព័ត៌មាន

- បានរៀបចំកម្មវិធីប្រគល់ និងទទួលម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគចំនួន០២គ្រឿង និងថ្នាំកំចាត់មេរោគកូវីដ១៩ (Covid-19) ពីសមាគមមិត្តភាពពាណិជ្ជកម្មចិនហ្វូជៀននៅកម្ពុជា និងសមាគមជួយសង្គ្រោះប្រជាជននៅកម្ពុជា

- បានចាត់ចែងពិធីប្រគល់-ទទួលអគារ១ខ្នងជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីប្រតិបត្តិការងារប្រចាំថ្ងៃ

- បានសាងសង់អគារ៤ខ្នង សម្រាប់ធ្វើជាការិយាល័យរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សាលប្រជុំ កន្លែងស្នាក់នៅ ឃ្លាំងដាក់សម្ភារៈ និងបន្ទប់ទឹក

- បានសង់រោងដែកប្រក់ដំបូលប៉ូលីកាបូណាត នៅសាលសិក្ខាសាលាខាងជើងសាលពិសេសកណ្ដាល និងសាលប្រជុំបណ្ណាល័យ

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានៅតាមសួនច្បារនានា ព្រមទាំងគៀរមែកឈើ និងដាំដើមឈើក្នុងបរិវេណព្រឹទ្ធសភាចំនួន១៣២ប្ញង់/៧៧ដើម

- បានប្តូរស្លាកលេខរថយន្តពីរដ្ឋ៣២ ទៅរដ្ឋ០១ថ្មី ចំនួន២២គ្រឿង

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣,២៥៩គ្រឿង/លើក

- បានរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោលរបស់ព្រឹទ្ធសភា

- បានសហការជាមួយក្រុមហ៊ុនកម្ចាត់សត្វកណ្តៀរ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន២៥៦លើក។

II-**លទ្ធផលការងារគាំទ្រលើមុខងារនាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣,០១៥ច្បាប់

- បានរៀបចំចាត់ចែង ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបសវនាការ សម្តែងការគួរសម ពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១២២លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ ចងទង់ជាតិ ចងបដា ពាក្យស្លោកចំនួន៥៦លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៨៦ច្បាប់ ស្មើនឹង១,៣២២នាក់, ធ្វើលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន៣០ច្បាប់ ស្មើនឹង៣០នាក់, និងធ្វើលិខិតឧទ្ទេសនាមមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦ច្បាប់ ស្មើនឹង១១៧នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣,០៣៦លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៧៥លើក មានអ្នកចូលរួមចំនួន៥,៧២៨នាក់

- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារប្រើប្រាស់ សម្ភារការិយាល័យ ភេសជ្ជៈ ព្រមទាំងអាហារសម្រន់ សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១,២៩២សំណើ

- បានចែកទឹកអាល់កុល ជែលលាងដៃសម្លាប់មេរោគ ថ្នាំVitaminC និងម៉ាស់ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និង និវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៣លើក

- បានថតចម្លងឯកសារចំនួន៣៨,៣៨៧ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៥៩០ក្បាល អស់ក្រដាសចំនួន៤៣៥,០០៧សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៩០០លើក ស្មើនឹង២០០១នាក់

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចចំនួន២១ច្បាប់

- បានផលិតទស្សនាវដ្តីប្រចាំខែមករា ដល់ខែកញ្ញា ឆ្នាំ២០២០ ចំនួន១០,៨០០ក្បាល

- បានផលិតខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧៧លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និងតាម Telegramចំនួន៥,២១៥លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៣៦៤លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១១៦លើក

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ រាជកិច្ច និងទស្សនាវដ្តីចំនួន១,៨៧៥ក្បាល និងព្រឹត្តិបត្រ កាសែតAKPចំនួន៤៧០ច្បាប់ ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅដាក់ លេខកូដសៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅ អ៊ុតក្របសៀវភៅ បញ្ចូលសៀវភៅកាសា អង់គ្លេសក្នុងកម្មវិធីកូហា (Library management system) ចំនួន២,៨១៧ក្បាល

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet, ជួសជុលម៉ាស៊ីនកុំព្យូទ័រ, ដាក់កម្មវិធី កំចាត់មេរោគ Update Files Antivirus, ព្រមទាំង Set upកម្មវិធី និង Share Printerចំនួន៦១៣គ្រឿង ព្រមទាំងបានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន១,៦២៣ប្រធានបទ

- បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន៧៣០ក្បាល

- បានផ្តល់សេវាការប្រើប្រាស់ Mail,Telegaram និងZoom ជាមធ្យោបាយសម្រាប់ដំណើរការបរន្តឯកសារផ្ទៃក្នុង និងការប្រជុំពីចម្ងាយជូនអគ្គលេខាធិការព្រឹទ្ធសភា

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៥៦លើក ស្មើនឹង៥៥នាក់។

III-**ទិសដៅការងារសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០**

-ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៥ និងទី៦ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ

-ត្រៀមបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី៤ នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០

-ត្រៀមប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ ២០២០ និងទិសដៅត្រីមាសទី៤ ឆ្នាំ២០២០។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើៈ

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសម៉ាឡេស៊ី

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

៦-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៩ នៃច្បាប់ស្តីពីសហជីព

៧-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ

៨-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

៩-សេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មក្រុងគីហ្គាលីនៃពិធីសារម៉ុងរ៉េអាល់ស្ដីពី សារធាតុបំផ្លាញស្រទាប់អូហ្សូន

១០-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃអនុសញ្ញាមីណាម៉ាតាស្ដីពីបារ៉ត

១១-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពី បត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

១២-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

១៣-សេចក្ដីព្រាងច្បាប់ស្ដីពី មូលបត្ររដ្ឋ

១៤-សេចក្ដីព្រាងច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

១៥-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋឥណ្ឌា

១៦-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការវិនិយោគរវាងបណ្ដារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

១៧-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយវិសោធនកម្មកិច្ចព្រមព្រៀងស្ដីពី ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន

១៨-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារដើម្បីអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ាន ស្ដីពីសេវាកម្ម

១៩-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្ដីពីការទទួលស្គាល់ទៅវិញទៅមកលើការផ្ដល់អាជ្ញាបណ្ណក្រុមអាកាសយានិក។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារ ជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+គណៈកម្មការទី៧ ជួបសវនាការជាមួយក្រសួងធម្មការ និងសាសនា

+គណៈកម្មការទី២, ទី៦, និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មទៅខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកោះកុង និងខេត្តព្រះសីហនុ។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន ចូលរួមកិច្ចប្រជុំ និងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមរយៈប្រព័ន្ធវីដេអូ Conference

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (Huawei, វិទ្យាស្ថានជាតិការទូត, និងដៃគូបណ្តុះបណ្តាលនានាៗល។)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាព ជូនស្ថាប័នឱ្យបានល្អប្រសើរ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-រៀបចំរបាយការណ៍ចំណូល ចំណាយថវិកាព្រឹទ្ធសភាប្រចាំឆ្នាំ២០២០ និងរៀបចំបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ កម្រិតរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមរៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធីលើមូលដ្ឋានរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានទាំង៥

-បន្តសហការជាមួយក្រុមការងារFMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ និងបំពាក់សម្ភារៈប្រជុំតាមរយៈប្រព័ន្ធវីដេអូ Conference

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក តាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលរួមអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-ត្រៀមបោះពុម្ពដំណាច់ឆ្នាំៈ ទិនានុលេខន៍ ប្រតិទិន និងបោះពុម្ពឯកសារសំខាន់ៗផ្សេងទៀត សម្រាប់បម្រើជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមបែងចែកប័ណ្ណរថយន្តឱ្យបានទាន់ពេលវេលា

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យសំខាន់ៗរួមមានៈ ពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ ពិធីគ្រងរាជសម្បត្តិព្រះមហាក្សត្រ បុណ្យឯករាជ្យជាតិ និងពិធីបុណ្យជាតិផ្សេងៗទៀតៗ

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងនព្វមាសនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរ៉ាប់រងការងារលើមុខងារទាំង៥ ជារួមបានទទួលលទ្ធផលល្អប្រសើរ ទោះបីស្ថិតក្នុងស្ថានភាពលំបាក និងស្មុគស្មាញយ៉ាងណាក៏ដោយ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានដោយរលូនៗ ទន្ទឹមនឹងនេះ បានផ្តោតការយកចិត្តទុកដាក់ចូលរួម

ប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ១៩។ ជាពិសេស ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន លើគ្រប់វិស័យនៃការងារប្រចាំថ្ងៃ តាមរយៈប្រព័ន្ធ Online និងរៀបចំកិច្ចប្រជុំនានាតាមរយៈប្រព័ន្ធវីដេអូ ទាំងផ្ទៃក្នុងស្ថាប័នក៏ដូចជាក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីធានានិរន្តភាពការងារឱ្យស្របតាមស្ថានភាពជាក់ស្តែង និងតម្រូវការចាំបាច់របស់ស្ថាប័ន និងប្រទេសជាតិ។

ស្របពេលជាមួយគ្នានេះដែរ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ចប់ការកសាងក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០២១-២០៣០) និងរៀបចំផែនការយុទ្ធសាស្ត្រ កែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការងារធនធានមនុស្សរបស់អគ្គនាយកដ្ឋានទាំង៥ ឱ្យស្របតាមការវិវត្តរីកចម្រើនថ្មីរបស់ស្ថាប័ន។

មន្ត្រីរាជការទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពការងារ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណ សកម្មភាពច្រើន លើការងារដែលមានវិសាលភាពកាន់តែធំទូលាយ រួមទាំងការឆ្លងកាត់វិញ្ញាសារលំបាក និងថ្មីៗជាច្រើនក្នុងបរិបទកូវីដ១៩។

ទាំងអស់គ្នាត្រូវត្រៀមរៀបចំផែនការសកម្មភាពឆ្នាំ២០២១ ឱ្យបានសមស្របនឹងផែនការយុទ្ធសាស្ត្រ១០ឆ្នាំ (២០២១-២០៣០) របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ប្រតិបត្តិការត្រូវបន្តឈរលើ 3E's៖ ប្រសិទ្ធភាព ប្រសិទ្ធផល និងការសន្សំសំចៃ។

ថ្ងៃច័ន្ទ ៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ